# ការណែនាំអំពីរបៀបបំពេញសៀវភៅចុះបញ្ជីស្ត្រីមកពិនិត្យផ្ទៃពោះ

# នៅសេវាពិនិត្យផ្ទៃពោះ

(សំរាប់ពន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដែលអនុវត្តការងារ Linked Response)

**ជួរទី ១ :** ល. រ (No)

គឺជាលេខរៀងតាមលំដាប់ដែលស្ត្រីមកពិនិត្យផ្ទៃពោះក្នុងខែនិមួយៗ ជារៀងរាល់ខែ។

លេខរៀងនេះត្រូវចាប់ផ្តើមពីលេខ ១ និងបន្តទៅលេខបន្តបន្ទាប់ទៀតរហូតដំណាច់ខែ។

**នៅពេលចាប់ផ្តើមខែថ្មីលេខរៀងនេះត្រូវចាប់ផ្តើមពីលេខ ១ ឡើងវិញ។**

**ជួរទី ២ :** កាលបរិច្ឆេទចុះឈ្មោះ (Date of registration)

គឺជា ថ្ងៃ ខែ ឆ្នាំ ដែលស្ត្រីមកពិនិត្យផ្ទៃពោះ។

**ជួរទី ៣ :** ពិនិត្យលើកទី ១ (Visit 1)

គឺជាការពិនិត្យផ្ទៃពោះលើកដំបូងក្នុងពេលមានផ្ទៃពោះ។ ត្រូវគូស (✓) នៅជួរនេះ

បើការពិនិត្យលើកនេះជាការពិនិត្យលើកទី១។

**ជួរទី ៤ :** ពិនិត្យលើកទី ២ (Visit 2)

គឺជាការពិនិត្យផ្ទៃពោះលើកទី២ ក្នុងកំឡុងពេលមានផ្ទៃពោះលើកនេះ។ ត្រូវគូសសញ្ញា (✓) នៅជួរ នេះ

បើការពិនិត្យលើកនេះជាការពិនិត្យលើកទី ២។

**ជួរទី ៥ :** ពិនិត្យលើកទី ៣ (Visit 3)

គឺជាការពិនិត្យផ្ទៃពោះលើកទី៣ ក្នុងកំឡុងពេលមានផ្ទៃពោះលើកនេះ។ ត្រូវគូសសញ្ញា (✓) នៅជួរ នេះ

បើការពិនិត្យលើកនេះជាការពិនិត្យលើកទី ៣។

**ជួរទី ៦ :** ពិនិត្យលើកទី ៤ (Visit 4)

គឺជាការពិនិត្យផ្ទៃពោះលើកទី៤ ក្នុងកំឡុងពេលមានផ្ទៃពោះលើកនេះ។ ត្រូវគូសសញ្ញា (✓) នៅជួរ នេះ

បើការពិនិត្យលើកនេះជាការពិនិត្យលើកទី ៤។

**ជួរទី ៧ :** ពិនិត្យលើកទី ៥ រឺ លើស (Visit 5 or more)

គឺជាការពិនិត្យផ្ទៃពោះលើកទី៥ រឺលើសពី ៥ ដង ក្នុងកំឡុងពេលមានផ្ទៃពោះលើកនេះ។

ត្រូវគូសសញ្ញា (✓) នៅជួរនេះ បើការពិនិត្យលើកនេះជាការពិនិត្យលើកទី ៥ រឺលើសពី ៥ ដង។

**ជួរទី ៨ :** ឈ្មោះស្ត្រីមានផ្ទៃពោះ (Name)

គឺជាឈ្មោះ ( **នាមត្រកូល និងនាមខ្លួន**) របស់ស្ត្រីដែលបានមកពិនិត្យផ្ទៃពោះ ។

**ជួរទី ៩ :** អាយុ (age)

គឺជាអាយុរបស់ស្ត្រីមានផ្ទៃពោះ ដែលបានមកពិនិត្យផ្ទៃពោះ **អាយុនេះគិតជាឆ្នាំ** ។

**ជួរទី ១០ :** លេខសៀវភៅសុខភាពមាតា ( ប័ណ្ណផ្កាឈូក) (Mothers 'health book number)

គឺជា**លេខសៀវភៅសុខភាពមាតា** ដែលបានផ្តល់ជូនស្ត្រីមានផ្ទៃពោះដើម្បីតាមដានសុខភាពរបស់គាត់ និងកូនក្នុងផ្ទៃ ។

**ជួរទី ១១ :** អាស័យដ្ឋាន (address)

គឺជាអាស័យដ្ឋាន( លេខផ្ទះ ភូមិ ឃុំ ស្រុក )ដែលស្ត្រីមានផ្ទៃពោះស្នាក់នៅបច្ចុប្បន្ននេះ ។ បើស្ត្រីនោះទៅរកស៊ីនៅឆ្ងាយ ត្រូវចុះអាស័យដ្ឋានដែលគាត់ស្នាក់នៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព ។

**ជួរទី ១២ :** បញ្ជូនមកពី : ឧទាហរណ៍បញ្ជូនមកពី HBC, OI/ART ….. (Refer from….) រឺមកដោយខ្លួន ឯង (self-referred) ។

គឺជាឈ្មោះសេវា អង្គការ រឺស្ថាប័ន ដែលបញ្ជូនស្ត្រីមកពិនិត្យផ្ទៃពោះ ។ ក្នុងជួរនេះត្រូវកត់ ត្រាថាតើស្ត្រីមកពិនិត្យផ្ទៃពោះដោយខ្លួនឯង រឺបញ្ជូនមកដោយសេវា អង្គការ រឺស្ថាប័ន ណាមួយ ។

**ជួរទី ១៣ :** អាយុផ្ទៃពោះ ( ពិនិត្យ និង កំណត់ដោយឆ្មប) (age of pregnancy)

គឺជាអាយុកូនក្នុងផ្ទៃរបស់ស្ត្រីគិតមកដល់ថ្ងៃដែលមកពិនិត្យផ្ទៃពោះ ។ អាយុផ្ទៃពោះនេះត្រូវ**គិតជា សប្តាហ៍** ។

**ជួរទី ១៤ :** ចំនួនផ្ទៃពោះ (gravida)

គឺជាចំនួនដងនៃការមានផ្ទៃពោះរបស់ស្ត្រី រួមបញ្ចូលទាំងការមានផ្ទៃពោះលើកនេះ ទាំងកូនរលូត កើត ស្លាប់ ផង ។

**ជួរទី ១៥ :** សំពាធឈាម (blood pressure)

គឺជាសំពាធឈាមរបស់ស្ត្រីមកពិនិត្យផ្ទៃពោះដែលពិនិត្យ និង កំណត់ដោយឆ្មប ។ ត្រូវសរសេរ ឬ នូវសំពាធឈាមដែលបានវាស់ឃើញជាក់ស្តែង ។ ឧ. 160/90 mmHg

**ជួរទី ១៦ :** ផ្ទៃពោះបំរុងមានគ្រោះថ្នាក់ (high risk of pregnancy)

គឺជាការកំណត់ដោយឆ្មបដែលពិនិត្យផ្ទៃពោះទៅតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិគាំពារមាតា និងទារកថាតើផ្ទៃពោះនេះជាផ្ទៃដែលអាចមានគ្រោះថ្នាក់ដល់ស្ត្រីដែរ ឬទេ ។ បើមានសញ្ញាគ្រោះថ្នាក់ត្រូវកត់ត្រានូវរាល់រោគសញ្ញាដែលនាំអោយមានគ្រោះថ្នាក់ដូចជា **ហើម លើសឈាម ធ្លាក់ឈាម ប្រកាច់ ស្លេកស្លាំង** ……………… ។ល ។

**ជួរទី ១៧ :** បានទទួលអាស៊ីតហ្វូលីក រឺជាតិដែក (Received folic acid/iron) ។

គឺជាការផ្តល់ជាតិដែក រី អាស៊ីតហ្វូលីកទៅដល់ស្ត្រីមានផ្ទៃពោះ ។ត្រូវសសេរនូវ ចំនួនគ្រាប់ថ្នាំដែលបាន ផ្តល់អោយនៅជួរនេះ បើស្រ្ទីមានផ្ទៃពោះបានទទួលជាតិដែក រី អាស៊ីតហ្វូលីក ដែលផ្តល់ដោយបុគ្គលិក សុខាភិបាលពេល មកពិនិត្យផ្ទៃពោះ ។

**ជួរទី ១៨ :** បានទទួលមេបង់ដាហ្សុល (Received mebendazol)

គឺជាការផ្តល់ឱសថមេបង់ដាហ្សុលដល់ស្ត្រីមានផ្ទៃពោះ ត្រូវសសេរនូវចំនួនគ្រាប់ថ្នាំដែលបានផ្តល់ អោយនៅជួរនេះបើសិនជា ស្ត្រីមានផ្ទៃពោះបានទទួលឱសថនេះពេលមក**ពិនិត្យផ្ទៃពោះលើកនេះ** ។

**ជួរទី ១៩ :**បានផ្តល់ថ្នាំបង្ការតេតាណូស (Given tetanus vaccin)

គឺជាការចាក់ថ្នាំបង្ការតេតាណូសដល់ស្ត្រីមានផ្ទៃពោះ ។ ត្រូវសសេរចំនួនដង( ឧ. **ចាក់លើកទី១** ឬ ចាក់ **លើកទី២....** )ដែលគាត់បានចាក់វ៉ាក់សាំងលើកនេះ នៅជួរនេះបើសិនជាស្ត្រីមានផ្ទៃពោះបានទទួល ការចាក់ថ្នាំបង្ការតេតាណូសនៅពេលមកពិនិត្យផ្ទៃពោះ ។

**ជួរទី ២០ :**ធ្លាប់បានធ្វើតេស្តឈាម រកមេរោគអេដស៍ ឬ ទេ ?( – ឬ +)(Received HIV test before: result + or -)

គឺជាការធ្វើតេស្តឈាមរកមេរោគអេដស៏កាលពីមុនមក ( មុនពេលមកពិនិត្យផ្ទៃពោះលើកនេះ) បើស្ត្រីនោះធ្លាប់ធ្វើតេស្ត HIV ត្រូវសួរពីលទ្ធផលតេស្តនោះ បើលទ្ធផលតេស្តវិជ្ជមានត្រូវគូស សញ្ញានេះ (+ ) បើលទ្ធផលអវិជ្ជមានត្រូវគូសសញ្ញា ( -) នៅក្នុងជួរនេះ ។

**ជួរទី ២១ :** ទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ( Pre Test counseiling ):

បើសិនជាស្ត្រីនោះបានទទួលការផ្តល់ប្រឹក្សាមុនពេលបូមឈាមធ្វើតេស្តរកមេរោគអេដស៏ ស្វាយ យើងត្រូវសរសេរក្នុង កូឡោននេះថា **បានធ្វើ** ។ បើមិនបានធ្វើត្រូវសរសេរថា **មិនបានធ្វើ** ។

**ជួរទី ២២ :** ស្ម័គ្រចិត្តធ្វើតេស្តឈាម និងបានបូមឈាមធ្វើតេស្តរកមេរោគអេដស៏ ស្វាយ ឬ អេម៉ូក្លូប៊ីន (Received test for HIV, Syphilis and Hemoglobin ) :

បើសិនជាស្ត្រីនោះបានស្ម័គ្រចិត្ត យល់ព្រមអោយយើងបូមឈាមយកមកធ្វើតេស្ត រកមេរោគអេដស៏ ស្វាយ ឬ អេម៉ូក្លូប៊ីន**ត្រូវសសេរថាយល់ព្រម** បើមិនស្ម័គ្រចិត្តត្រូវសសេរថា**មិនយល់ព្រម** នៅក្នុងជួរនេះ ។

**ជួរទី ២៣ :** លេខកូដសំណាកឈាម (blood sample code)

បើស្ត្រីមានផ្ទៃពោះស្ម័គ្រចិត្តអោយបូមឈាមត្រូវចុះលេខកូដសំណាកឈាមក្នុងជួរនេះដែលមានលេខ ទាំងអស់ចំនួន ៥ ខ្ទង់ នាំមុខដោយអក្សរ w ចំពោះស្ត្រី ដោយចាប់ផ្តើមពីលេខ **w0000១** និងនាំមុខ ដោយអក្សរ **H** ចំពោះដៃគូរបស់គាត់ (លេខកូដត្រូវយកតាមលេខកូដរបស់ស្ត្រីជាដៃគូ) រួចឡើងតាម លំដាប់លេខរៀងរហូតទៅ **ទោះបីដាច់ខែ ឬ ដំណាច់ឆ្នាំក៏ដោយ គឺមិនត្រឡប់មកលេខ 0000១ វិញឡើយ** ។

**ជួរទី ២៤ :** កាលបរិច្ឆេទត្រូវត្រឡប់មកយកលទ្ធផលតេស្តឈាម (Date to return for test result)

ត្រូវចុះកាលបរិច្ឆេទទាំង ថ្ងៃ ខែ ឆ្នាំ ដែលត្រូវអោយគាត់ត្រឡប់មកយកលទ្ធផលតេស្តនៅក្នុង ជួរនេះ ។

**ជួរទី ២៥** ទី **២៦** និង ទី **២៧ :** លទ្ធផលតេស្តឈាម (Test result) **:**

**ជួរទី ២៥ :** តេស្ត HIV ( – ឬ + ឬ កំណត់មិនបាន)

បើលទ្ធផលតេស្ត**អវិជ្ជមាន**ត្រូវគូសសញ្ញានេះ ( – ) ក្នុងជួរនេះ ។

បើលទ្ធផលតេស្ត**វិជ្ជមាន**ត្រូវគូសសញ្ញានេះ (+) ក្នុងជួរនេះ ។

បើលទ្ធផលតេស្ត**មិនអាចកំណត់បាន** ត្រូវសរសេរក្នុងជួរនេះថា **កំណត់មិនបាន**

**ជួរទី ២៦ :** តេស្តរកមេរោគស្វាយ RPR ( – ឬ +)

លទ្ធផលតេស្តរកមេរោគស្វាយនេះយើងមិនរាប់បញ្ចូលនូវតេស្តរហ័ស (Rapid test)

នោះទេ គឺយើងយកតែតេស្ត **RPR មួយគត់** ដូចនេះបើលទ្ធផលៈ

- តេស្ត RPR **អវិជ្ជមាន**ត្រូវគូស ( –) ក្នុងជួរនេះ ។
- តេស្ត RPR **វិជ្ជមាន**ត្រូវគូស (+) ក្នុងជួរនេះ ។

**ជួរទី ២៧ :** តេស្តអេម៉ូក្លូប៊ីន (Hemoglobin test)

ត្រូវកត់ត្រាចូលក្នុងជួរនេះនូវលទ្ធផលតេស្តអេម៉ូក្លូប៊ីនទៅតាមលទ្ធផលរបស់មន្ទីរពិសោធន៍ ។ ឧ. ប៉ុន្មាន ក្រាម/១០០មីលីលីត្រ ។

**ជួរទី ២៨ :** កាលបរិច្ឆេទបានផ្តល់លទ្ធផលតេស្តឈាមដល់អតិថិជន (Date provided test result to clients)

ត្រូវកត់ចូលក្នុងជួរនេះនូវ ថ្ងៃ ខែ ឆ្នាំ ដែលអតិថិជនបានមកទទួលលទ្ធតេស្តឈាម ។

**ជួរទី ២៩** និង **ទី ៣០ :** ការធ្វើតេស្តឈាមរបស់ដៃគូ (Partner's test) **:**

ត្រូវសួរស្ត្រីមានផ្ទៃពោះថា ដៃគូរបស់គាត់បានធ្វើតេស្តរកមេរោគអេដស៍ ឬ ស្វាយហើយឬនៅ :

-បើមិនទាន់បានធ្វើតេស្តត្រូវលើកទឹកចិត្តអោយគាត់អោយគាត់នាំដៃគូមកធ្វើតេស្ត ។

-បើបានធ្វើតេស្តហើយ ត្រូវកត់ត្រាលទ្ធផលដូចខាងក្រោមនេះ :

- **ជួរទី ២៩ :** តេស្ត HIV ( – ឬ + ឬ កំណត់មិនបាន)

  បើលទ្ធផលតេស្ត HIV **អវិជ្ជមាន**ត្រូវគូសសញ្ញានេះ ( –) ក្នុងជួរនេះ ។

  បើលទ្ធផលតេស្ត HIV **វិជ្ជមាន**ត្រូវគូសសញ្ញានេះ (+) ក្នុងជួរនេះ ។

  បើលទ្ធផលតេស្ត HIV **មិនអាចកំណត់បាន**ត្រូវសរសេរក្នុងជួរនេះថា **កំណត់មិនបាន** ។

- **ជួរទី ៣០ :** តេស្តរកមេរោគស្វាយ RPR ( – ឬ +)

លទ្ធផលតេស្តរកមេរោគស្វាយនេះយើងមិនរាប់បញ្ចូលនូវ តេស្តរហ័ស (Rapid test)

នោះទេគឺយើងយកតែតេស្ត **RPR មួយគត់** ដូចនេះបើលទ្ធផល:

- តេស្ត RPR អវិជ្ជមានត្រូវគូស (-) ក្នុងជួរនេះ ។

- តេស្ត RPR វិជ្ជមានត្រូវគូស (+) ក្នុងជួរនេះ ។

**ជួរទី ៣១ :** បញ្ជូនទៅសេវាអ្វី ? (Refered to)

គឺត្រូវកត់ត្រារាល់ការបញ្ជូនគាត់ទៅកាន់សេវាផ្សេង ៗ ដូចជាឧទាហរណ៍ខាងក្រោមនេះ :

បើបញ្ជូនគាត់ទៅសេវា OI/ART ត្រូវកត់ត្រានៅក្នុងជួរនេះ OI/ART

បើបញ្ជូនគាត់ទៅសេវាព្យាបាលរបេង ត្រូវកត់ត្រានៅក្នុងជួរនេះ TB

បើបញ្ជូនគាត់ទៅសេវាព្យាបាលជំងឺកាមរោគ ត្រូវកត់ត្រានៅក្នុងជួរនេះ STI

បើបញ្ជូនគាត់ទៅមន្ទីរពេទ្យបង្អែក ត្រូវកត់ត្រានៅក្នុងជួរនេះ RH

**ជួរទី ៣២ :** តំលៃសេវា (User fee paid)

គឺត្រូវកត់ត្រាអោយបានច្បាស់លាស់នូវចំនួនទឹកប្រាក់ដែលគាត់បានបង់ចូលសេវារបស់មណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក រៀងរាល់ពេលគាត់មកពិនិត្យ ។

**ជួរទី ៣៣ :** សំគាល់ (Remark): ត្រូវកត់ត្រានូវរាល់ពត៌មានសំខាន់ផ្សេងៗទៀតដែលទាក់ទងនឹងស្ត្រី និងសេវា ដែលបានផ្តល់អោយគាត់ ។

ឧ. បើការពិនិត្យផ្ទៃពោះធ្វើឡើងនៅមណ្ឌលសុខភាព ត្រូវចុះក្នុងជួរនេះថា ពិនិត្យផ្ទៃពោះនៅ HC

បើការពិនិត្យផ្ទៃពោះធ្វើឡើងនៅតាមសហគមន៍ ត្រូវចុះក្នុងជួរនេះថា ពិនិត្យផ្ទៃពោះនៅ តាមសហគមន៍ ។